អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង

ដោយបានទទួលការតែងតាំងតាមរយៈព្រះរាជក្រឹត្យចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឲ្យមកបំពេញការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់រយៈពេលនៃកិច្ចដំណើរការនីតិវិធីទាំងមូល ដោយទទួលបានការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា និងបន្ទាប់ពីបានស្បថនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រូវបានតែងតាំងតាមផ្លូវច្បាប់ដើម្បីជំនួសចៅក្រមមុន និងដើម្បីទទួលកាន់តួនាទីដែលចៅក្រមមុនបានអនុវត្តរហូតដល់ពេលដែលគាត់បានលាលែងពីតំណែងយ៉ាងលឿន ចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១ (មាត្រា១២, ២៣, ២៦ និង ២៧ នៃច្បាប់ អ.វ.ត.ក)។

បន្ទាប់ពីបានបំពេញការងារតាមអាណត្តិរបស់ខ្លួនតាមមធ្យោបាយពីចម្ងាយពីប្រទេសក្រៅតាំងពីថ្ងៃទី ១៤ ខែ វិច្ឆិកា ដោយអនុលោមតាមវិធាន ១៤ (៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បច្ចុប្បន្ន លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានបំពេញការងារនៅការិយាល័យរបស់គាត់នៅទីក្រុងភ្នំពេញហើយ។ ក្នុងការគោរពតាមគោលការណ៍នៃការយកចិត្តទុកដាក់សមស្រប (វិធាន ២១.៤ នៃវិធានផ្ទៃក្នុង) សហចៅក្រមអន្តរជាតិបម្រុង រួមជាមួយនឹងសហចៅក្រមជាតិ នឹងចាត់ចែងធ្វើកិច្ចស៊ើបសួរ ព្រមទាំងចាត់វាល់វិធានការចាំបាច់នានាដើម្បីគ្រប់គ្រងការិយាល័យរបស់ខ្លួន។

លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង រួមជាមួយនឹងសហចៅក្រមជាតិ ដោយអនុលោមតាមវិធាន ៥៦ (២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នឹងព្យាយាមផ្តល់ព័ត៌មានទៅសាធារណជនឲ្យបានគ្រប់គ្រាន់អំពីការវិវឌ្ឍន៍សំខាន់ៗនៅក្នុងសំណុំរឿង ០០៣ និង ០០៤។